# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខៈ ០៤១ គ.ជ.ប. ស.ជ.ណ

# សេចក្ដីជូនដំណឹង

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ត្រូវការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) ចំនួន **១៤២.៧៣៤**រូប ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាមគណៈកម្មការការិយាល័យបោះឆ្នោតនូទាំងប្រទេសសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣ ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត | ចំនួន ១ រូប |
| ២- អនុប្រធានគណៈកម្មការការិយាល័យបោះឆ្នោត | ចំនួន ១ រូប |
| ៣- លេខាធិការ | ចំនួន ១ រូប |
| ៤- សមាជិកទី១ | ចំនួន ១ រូប |
| ៥- សមាជិកទី២ | ចំនួន ១ រូប |
| ៦- សមាជិកទី៣ | ចំនួន ១ រូប។ |

សាធារណជន ដែលមានបំណងដាក់ពាក្យសុំចូលបម្រើការងារតាមមុខតំណែងខាងលើ សូមអញ្ជើញមកទទួល និងដាក់ពាក្យ សុំចូលបម្រើការងារនៅរៀងរាល់ម៉ោងធ្វើការនៅតាមគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត (គឃ.សប) ឬ/និងទីសាធារណៈក្នុងឃុំ សង្កាត់ ដែលកំណត់ដោយ គឃ.សប ពាក់ព័ន្ធ។

ពាក្យសុំចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃ។ បេក្ខជនអាចទាញយកពាក្យសុំប្រឡងចូលបម្រើការងារតាមរយៈគេហទំព័ររបស់ គ.ជ.ប អាសយដ្ឋាន (www.nec.gov.kh) ឬស្កេន QR-Code ដូចមាននៅក្នុងសេចក្ដីជូនដំណឹងនេះ។

- ការចាប់ផ្ដើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣។
- ការឈប់ទទួលពាក្យ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)។

ថ្ងៃ ចន្ទ ៣កើត ខែ ជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០២៣
ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ប្រធាន

ប្រាជ្ញ ចន្ទ

ស្កេន QR-Code

ដើម្បីទាញយកពាក្យសុំចូលបម្រើការងារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
លេខ: ០៤២ គ.ជ.ប. ស.ជ.ណ

# សេចក្ដីជូនដំណឹង
## ស្ដីពី
## លក្ខខណ្ឌនៃការជ្រើសរើស និងភារកិច្ចរបស់សមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត (គធ.ខប) ទាំង២៥ ត្រូវការជ្រើសរើសសមាសភាពគណៈកម្មការការិយាល័យបោះឆ្នោត (គ.ក.ប) សរុបចំនួន **១៤២.៧៣៤ រូប** ជាមន្ត្រីជាប់កិច្ចសន្យារយៈពេលខ្លី ដើម្បីបម្រើការងារនៅតាមគណៈកម្មការការិយាល័យបោះឆ្នោតនីមួយៗ ដែលមានមុខតំណែងដូចខាងក្រោម ៖

| | |
|---|---|
| ១- ប្រធាន | ចំនួន ១ រូប |
| ២- អនុប្រធាន | ចំនួន ១ រូប |
| ៣- លេខាធិការ | ចំនួន ១ រូប |
| ៤- សមាជិកទី១ | ចំនួន ១ រូប |
| ៥- សមាជិកទី២ | ចំនួន ១ រូប |
| ៦- សមាជិកទី៣ | ចំនួន ១ រូប ។ |

**I- លក្ខខណ្ឌទូទៅសម្រាប់ជ្រើសរើសសមាសភាព គ.ក.ប ៖**

- ជាប្រជាពលរដ្ឋ ឬ/និងមន្ត្រីរាជការដែលរស់នៅក្នុងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ឆ្នាំឡើងទៅ គិតដល់ថ្ងៃតែងតាំង
- មានសិទ្ធិបោះឆ្នោត
- ត្រូវចេះអាន និងសរសេរអក្សរខ្មែរច្បាស់លាស់
- មានបទពិសោធន៍ការងារពាក់ព័ន្ធ
- មិនត្រូវជាសហព័ទ្ធ ឬញាតិលោហិត ឬញាតិពន្ធរហូតដល់ថ្នាក់ទី៣ នៅក្នុងគណៈកម្មការតែមួយ
- មានកិរិយាមារយាទល្អ និងសុចរិតទៀងត្រង់ គោរពច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប និងក្រមសីលធម៌មន្ត្រីបោះឆ្នោត
- មានសុខភាពល្អ

- មានលទ្ធភាពបំពេញការងារពេញម៉ោង
- មិនមែនជាកងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ
- មិនមែនជាមន្ត្រីតុលាការក្នុងក្របខណ្ឌការងារ
- មិនមែនជាព្រះសង្ឃ ឬបព្វជិតសាសនា
- មិនមែនជាអភិបាល អភិបាលរងក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- មិនមែនជាមេភូមិ អនុប្រធានភូមិ ឬសមាជិកភូមិ
- មិនមែនជាជនដែលតុលាការផ្តន្ទាទោស ដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ
- ប្រធាន អនុប្រធាន លេខាធិការ និងសមាជិក គ.ក.ប ដែលជាសមាជិកគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងមន្ត្រីរាជការ ក្រោយពីបានទទួលការតែងតាំង ត្រូវលាលែងបណ្តោះអាសន្នពីសមាជិកនៃគណបក្សនយោបាយ ឬ/និងអ្នកដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម សហជីព ឬ/និងត្រូវដាក់ពាក្យសុំច្បាប់ឈប់សម្រាកពីការងាររហូតដល់ថ្ងៃចប់ភារកិច្ច
- បេក្ខនារី ឬ បេក្ខជន និងបេក្ខនារីដែលជាជនជាតិដើមភាគតិចនៅតំបន់ដែលមានជនជាតិដើមភាគតិចតាមចំនួនសមស្រប និងចំពោះបេក្ខជន និងបេក្ខនារីជាជនមានពិការភាពដែលមានសមត្ថភាព និងកាយសម្បទាសមស្របទៅនឹងមុខតំណែងត្រូវបានលើកទឹកចិត្ត។

## II- ភារកិច្ចទទួលខុសត្រូវរបស់សមាសភាព គ.ក.ប ត្រូវបានកំណត់ដូចខាងក្រោម ៖

គ.ក.ប មានភារកិច្ចចាត់ចែងគ្រប់គ្រង និងត្រួតពិនិត្យនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោតដែល គ.ក.ប នោះទទួលខុសត្រូវ។

**១- ប្រធាន គ.ក.ប មានភារកិច្ចទទួលខុសត្រូវដូចខាងក្រោម ៖**

- ចាត់ចែង និងគ្រប់គ្រងនូវរាល់កិច្ចប្រតិបត្តិការបោះឆ្នោត និងរាប់សន្លឹកឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត ដែលខ្លួនទទួលខុសត្រូវ
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតស្របតាមច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងការណែនាំរបស់ គ.ជ.ប
- ទទួលពិនិត្យ ផ្ទៀងផ្ទាត់ និងការពារឱ្យបានហ្មត់ចត់នូវរាល់សម្ភារ ឯកសារ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ពិសេសពិនិត្យលេខកូដនៃកញ្ចប់សន្លឹកឆ្នោតដើម្បីឱ្យប្រាកដថា ពិតជាសន្លឹកឆ្នោតសម្រាប់ឃុំ សង្កាត់ខ្លួន
- បោះទីតាំង រៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត និងបំពាក់គ្រឿងសង្ហារិម
- តាមដាន និងត្រួតពិនិត្យការបំពេញការងាររបស់សមាសភាព គ.ក.ប នៅថ្ងៃបោះឆ្នោត និងរាប់សន្លឹកឆ្នោត ក្នុងការិយាល័យរបស់ខ្លួន
- ដាក់ជំនួសតំណែងសមាជិក គ.ក.ប ណាដែលមិនបានមកបំពេញការងារបោះឆ្នោតតាមកិច្ចសន្យា

- ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការបោះឆ្នោតក្នុងការិយាល័យបោះឆ្នោត។ ក្នុងពេលកំពុងដំណើរការបោះឆ្នោតយ៉ាងយូរ ១(មួយ) ម៉ោងម្ដង ត្រូវចូលក្នុងបន្ទប់សម្ងាត់ ដើម្បីត្រួតពិនិត្យសុវត្ថិភាព សម្ភារដែលបំពាក់នៅទីនោះ និងសណ្ដាប់ធ្នាប់ ក្នុងករណីគ្មានអ្នកបោះឆ្នោតនៅក្នុងបន្ទប់សម្ងាត់
- ធានាឱ្យប្រាកដថា គ្រប់កំណត់ហេតុ និងទម្រង់បែបបទទាំងអស់ពាក់ព័ន្ធនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោតត្រូវបានបំពេញ និងចុះហត្ថលេខាត្រឹមត្រូវ និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយចុះហត្ថលេខា ឬផ្ដិតមេដៃជាសាក្សី
- ត្រួតពិនិត្យលិខិតតែងតាំង និងទទួលស្គាល់ភ្នាក់ងារគណបក្សនយោបាយ និងលិខិតតែងតាំង និងទទួលស្គាល់អ្នកសង្កេតការណ៍ ដែលត្រូវចូលរួមសង្កេតមើលការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- សម្របសម្រួលឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ផ្លាស់ប្ដូរទីកន្លែងពិនិត្យមើលដំណើរការការងារក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត
- ត្រួតពិនិត្យ និងបង្ហាញហិបឆ្នោតដល់អ្នកដែលមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត
- បើក និងបិទកិច្ចប្រតិបត្តិការបោះឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត
- ធានារបៀបរៀបរយក្នុង និងក្រៅបរិវេណការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ចាក់ ឬកាត់ផ្ដាច់សោឃ្លុំការពារហិបឆ្នោត
- ធានាឱ្យប្រាកដថា អ្នកបោះឆ្នោតម្នាក់ៗត្រូវបានណែនាំឱ្យចេះពីរបៀបបោះឆ្នោត និងតាមដានពិនិត្យមើល ដើម្បីឱ្យប្រាកដថា នៅពេលចេញពីបន្ទប់សម្ងាត់ អ្នកបោះឆ្នោតបានបត់សន្លឹកឆ្នោតតាមផ្នត់ដើមដូចការណែនាំ
- ធានាឱ្យប្រាកដថា ការប្រើប្រាស់ទឹកខ្មៅលុបមិនជ្រះ ត្រូវតែបានអនុវត្តតាមការណែនាំ
- ធានាឱ្យប្រាកដថា ការលើកយោបល់តវ៉ា ឬជំទាស់ និងការប្ដឹងតវ៉ា ឬ/និងប្ដឹងជំទាស់ក្នុងការិយាល័យបោះឆ្នោត ដោយភ្នាក់ងារគណបក្សនយោបាយ ស្របតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ត្រូវបានដោះស្រាយភ្លាម ដោយអនុវត្តស្របតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងការណែនាំរបស់ គ.ជ.ប
- ជួយអ្នកបោះឆ្នោតជាជនមានពិការភាព ដែលមិនអាចបោះឆ្នោតដោយខ្លួនឯង តាមការស្នើសុំ
- ចាត់ចែង និងត្រួតពិនិត្យកិច្ចប្រតិបត្តិការផ្ទៀងផ្ទាត់ និងរាប់សន្លឹកឆ្នោត
- ត្រួតពិនិត្យសុពលភាពសន្លឹកឆ្នោត និងប្រកាសឈ្មោះគណបក្សនយោបាយ ដែលបានទទួលសំឡេងឆ្នោត
- ចាត់ចែងបិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត តាមការកំណត់ដោយច្បាប់ និងបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប

- ប្រគល់ជូន គឃ.សប នូវកំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត
- ប្រគល់ជូន គឃ.សប នូវកំណត់ហេតុស្តីពីការបោះឆ្នោត និងហិបឆ្នោតដែលមានសន្លឹកឆ្នោតខាងក្នុង ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀត ក្នុងករណីប្រធានសក្តិ ឬកាលៈទេសៈមានអាសន្នដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតបាន
- បំពេញភារកិច្ចរបស់ខ្លួនក្នុងជំហរអព្យាក្រឹត និងមិនលម្អៀង
- បំពេញភារកិច្ចផ្សេងៗទៀតដែល គឃ.សប ប្រគល់ឱ្យ។

**២- អនុប្រធាន គ.ក.ប មានភារកិច្ចដូចខាងក្រោម ៖**

- ជួយការងារប្រធាន គ.ក.ប
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងការណែនាំ របស់ គ.ជ.ប
- ជួសតំណែងប្រធាន ក្នុងករណីប្រធានមិនអាចមកបំពេញការងារបាន
- រាប់ចំនួនសន្លឹកឆ្នោតដែលបានទទួលជាក់ស្តែង សម្រាប់ប្រើក្នុងការិយាល័យបោះឆ្នោតមុននឹងបើកកិច្ចប្រតិបត្តិការបោះឆ្នោត
- ហែកសន្លឹកឆ្នោតផ្តាច់ចេញពីគល់បញ្ជីសៀវភៅសន្លឹកឆ្នោត បោះត្រាសម្ងាត់លើផ្នែកខាងខ្នង និងបត់ជា ៤ (បួន) ផ្ទត់តាមការណែនាំរបស់ គ.ជ.ប រួចប្រគល់ជូនអ្នកបោះឆ្នោត
- ផ្តល់ការណែនាំស្តីពីនីតិវិធីនៃការបោះឆ្នោតដល់អ្នកបោះឆ្នោត
- អនុញ្ញាតឱ្យអ្នកបោះឆ្នោតចូលគូសសន្លឹកឆ្នោតក្នុងបន្ទប់សម្ងាត់ នៅពេលដែលបន្ទប់សម្ងាត់នោះទំនេរ គ្មានអ្នកបោះឆ្នោតផ្សេងទៀត
- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត នៅពេលបញ្ចប់ការបោះឆ្នោត
- ត្រួតពិនិត្យ និងបែងចែកប្រភេទសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់នៅខាងខ្នងមុននឹងប្រគល់ជូនប្រធាន
- កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗ បានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត
- អមដំណើរប្រធាន គ.ក.ប ក្នុងការបញ្ជូន និងប្រគល់កំណត់ហេតុនៃការបោះឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ព្រមទាំងសម្ភារ ឯកសារបោះឆ្នោតផ្សេងទៀតជូន គឃ.សប
- បំពេញភារកិច្ចផ្សេងទៀតដែល គឃ.សប និងប្រធាន គ.ក.ប ប្រគល់ឱ្យ។

៣- លេខាធិការនៃ គ.ក.ប មានភារកិច្ចដូចខាងក្រោម ៖

- ពិនិត្យភាពត្រឹមត្រូវនៃអ្នកបោះឆ្នោត ព្រមទាំងការបំពេញទម្រង់បែបបទទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- ម្ចាស់ការក្នុងការអនុវត្តគ្រប់ដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ស្របតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត និងការណែនាំរបស់ គ.ជ.ប
- ជួយប្រធាន គ.ក.ប ក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត និងរាប់សន្លឹកឆ្នោត
- ជួយប្រធាន គ.ក.ប ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប
- ត្រួតពិនិត្យរកមើលស្នាមទឹកខ្មៅលុបមិនជ្រះ នៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថាគាត់បានបោះឆ្នោតហើយ ឬមិនទាន់បោះឆ្នោត នៅមុនពេលពិនិត្យឈ្មោះរបស់គាត់នៅក្នុងបញ្ជីបោះឆ្នោត
- ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ភាពដូចគ្នារវាងរូបពិត ឈ្មោះ និងទិន្នន័យ ក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (អ.ខ) ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការបោះឆ្នោត ( ឯ.អ ) របស់សាមីអ្នកបោះឆ្នោតជាមួយនឹងរូបថត ឈ្មោះ និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត រួចគូសសម្គាល់ថាបានមកបោះឆ្នោត ក្នុងប្រអប់បួនជ្រុងតូចទន្ទឹមនឹងឈ្មោះអ្នកបោះឆ្នោតនោះលើបញ្ជីបោះឆ្នោត
- រាប់គំនូសសញ្ញាលើបញ្ជីបោះឆ្នោត និងរាយការណ៍ជូនប្រធាន គ.ក.ប អំពីចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងមិនបានបោះឆ្នោត
- បំពេញកំណត់ហេតុនៃការបោះឆ្នោត និងដាក់ជូនប្រធានចុះហត្ថលេខា រួចដាក់បង្ហាញឱ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល
- កត់ត្រាក្នុងកំណត់ហេតុនូវរាល់ការលើកយោបល់តវ៉ា ឬជំទាស់ ឬករណីប្តឹងតវ៉ា និងប្តឹងជំទាស់ទាក់ទងនឹងការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗបានទទួលនៅលើតារាងកត់ត្រាសំឡេងឆ្នោត
- បំពេញកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត និងដាក់ជូនប្រធាន គ.ក.ប ចុះហត្ថលេខា បន្ទាប់មកដាក់បង្ហាញភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើល និងអញ្ជើញភ្នាក់ងារគណបក្សនយោបាយ ចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី
- បំពេញភារកិច្ចផ្សេងទៀតដែល គឃ.សប និងប្រធាន គ.ក.ប ប្រគល់ឱ្យ។

**៤- សមាជិកទី១ នៃ គ.ក.ប មានភារកិច្ចដូចខាងក្រោម ៖**

- ជួយប្រធាន គ.ក.ប ក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- ជួយប្រធាន គ.ក.ប ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ដែលកំណត់ដោយ គ.ជ.ប
- ត្រួតពិនិត្យហិបឆ្នោត និងការស៊កសន្លឹកឆ្នោតចូលក្នុងហិបឆ្នោត ក្នុងពេលកំពុងដំណើរការបោះឆ្នោត
- រាយការណ៍ជូនប្រធាន គ.ក.ប ក្នុងករណីពិនិត្យឃើញថា អ្នកបោះឆ្នោតណាម្នាក់បានស៊កសន្លឹកឆ្នោតក្លែងក្លាយ ឬវត្ថុផ្សេងទៀតចូលក្នុងហិបឆ្នោត
- ជ្រលក់ម្រាមដៃរបស់អ្នកបោះឆ្នោត ដែលបានបោះឆ្នោតរួចហើយម្នាក់ម្តងៗទៅក្នុងទឹកខ្មៅលុបមិនជ្រះឱ្យដល់គល់ក្រចក និងណែនាំគាត់ឱ្យរង់ចាំបន្តិច ដើម្បីឱ្យទឹកខ្មៅស្ងួត មុននឹងចេញពីការិយាល័យបោះឆ្នោត
- រាប់ចំនួនសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីផ្ទៀងផ្ទាត់ទៅនឹងចំនួនអ្នកបោះឆ្នោតដែលបានបោះឆ្នោត និងដកយកវត្ថុមិនមែនជាសន្លឹកឆ្នោត (បើមាន) ដាក់ទៅក្នុងស្រោមសំបុត្រដោយឡែក
- លាសន្លឹកឆ្នោតដែលចាក់ចេញពីហិបឆ្នោត ដើម្បីត្រួតពិនិត្យស្លាកត្រាសម្ងាត់នៅផ្នែកខាងខ្នង និងបែងចែកតាមពំនូកសន្លឹកឆ្នោតមានត្រាសម្ងាត់ ឬគ្មានត្រាសម្ងាត់
- កត់ត្រាសំឡេងឆ្នោត ដែលគណបក្សនយោបាយនីមួយៗបានទទួលនៅលើផ្ទាំងក្រដាសធំ
- បំពេញភារកិច្ចផ្សេងទៀតដែល គឃ.សបប និងប្រធាន គ.ក.ប ប្រគល់ឱ្យ ។

**៥- សមាជិកទី២ នៃ គ.ក.ប មានភារកិច្ចដូចខាងក្រោម៖**

- ជួយប្រធាន គ.ក.ប ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោត តាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- ជួយរកឈ្មោះអ្នកបោះឆ្នោត នៅក្នុងបញ្ជីបោះឆ្នោតដែលបិទនៅខាងក្រៅការិយាល័យបោះឆ្នោត និងប្រាប់លេខរៀងឈ្មោះរបស់គាត់
- ចាត់ចែង និងថែរក្សារបៀបរៀបរយជូនអ្នកបោះឆ្នោត (ក្នុងករណីចាំបាច់ អាចផ្តល់បណ្ណលេខរៀងតាមលំដាប់អ្នកមកមុនមកក្រោយ) ព្រមទាំងរាយការណ៍ជូនប្រធាន គ.ក.ប អំពីការរំខាន ឬការអុកឡុកនានា ក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត (បើមាន)
- រាយការណ៍ជូនប្រធាន គ.ក.ប ក្នុងករណីពិនិត្យឃើញថា មានអ្នកបោះឆ្នោតណាម្នាក់បានយកសន្លឹកឆ្នោតផ្លូវការចេញពីការិយាល័យបោះឆ្នោត

- ប្រមូល អ.ខ ឬ ឯ.អ ពីអ្នកបោះឆ្នោត ដែលស្ថិតក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោត នៅពេលដល់ម៉ោងបញ្ចប់ការបោះឆ្នោតម៉ោង ១៥:០០ (ដប់ប្រាំ) រសៀល បើមាន
- បោះសន្លឹកឆ្នោត ដែលនៅសល់មិនបានប្រើប្រាស់ បន្ទាប់ពីបញ្ចប់ការផ្ទៀងផ្ទាត់សន្លឹកឆ្នោត
- សហការជាមួយសមាជិកទី៣ ក្នុងការការពារមាត់ទ្វារការិយាល័យបោះឆ្នោត ការថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់ក្នុងការិយាល័យរាប់សន្លឹកឆ្នោត
- បិទផ្សាយកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត
- នាំយកកំណត់ហេតុនៃការបោះឆ្នោត តារាងកត់ត្រាសំឡេងឆ្នោត និងកំណត់ហេតុនៃការរាប់សន្លឹកឆ្នោត ១ (មួយ) ច្បាប់ ទៅប្រគល់ជូន គឃ.សប
- បំពេញភារកិច្ចផ្សេងទៀតដែល គឃ.សប និងប្រធាន គ.ក.ប ប្រគល់ឱ្យ។

**៦- សមាជិកទី៣ នៃ គ.ក.ប មានភារកិច្ចដូចខាងក្រោម៖**

- ជួយប្រធាន គ.ក.ប ក្នុងការគ្រប់គ្រងសម្ភារ ឯកសារបោះឆ្នោត
- ចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តដំណើរការនៃការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត
- ជួយប្រធាន គ.ក.ប ក្នុងការរៀបចំការិយាល័យបោះឆ្នោត និងរាប់សន្លឹកឆ្នោតតាមគំរូប្លង់ ដែលកំណត់ដោយ គ.ជ.ប
- ត្រួតពិនិត្យច្រកទ្វារចូលនៃការិយាល័យបោះឆ្នោត ណែនាំអ្នកបោះឆ្នោតឱ្យឈរបន្តកន្ទុយគ្នាតាមលំដាប់មុនក្រោយ ប្រសិនបើគាត់ត្រូវបោះឆ្នោតនៅការិយាល័យបោះឆ្នោតនេះ និងត្រួតពិនិត្យ អ.ខ ឬ ឯ.អ របស់គាត់
- ផ្តល់អាទិភាពចូលក្នុងការិយាល័យបោះឆ្នោត ចំពោះអ្នកបោះឆ្នោតជាព្រះសង្ឃ មនុស្សចាស់ជរា ស្ត្រីមានផ្ទៃពោះ ជនដែលមានពិការភាព និងអ្នកមានជំងឺ បន្ទាប់មកគឺអ្នកឈរខាងមុខគេក្នុងជួរ
- ត្រួតពិនិត្យស្នាមទឹកខ្មៅលុបមិនជ្រះនៅលើម្រាមដៃអ្នកបោះឆ្នោត ដើម្បីឱ្យបានដឹងថា គាត់បានបោះឆ្នោតហើយ ឬមិនទាន់បានបោះឆ្នោត
- ជួយចាត់ចែង និងថែរក្សារបៀបរៀបរយក្នុងការិយាល័យបោះឆ្នោត និងរាយការណ៍អំពីការអុកឡុករំខានជូនប្រធាន គ.ក.ប
- សហការជាមួយសមាជិកទី២ ក្នុងការការពារសន្តិសុខនៅច្រកផ្លូវចូលការិយាល័យបោះឆ្នោត ថែរក្សាសម្ភារ ឯកសារបោះឆ្នោត និងចាត់ចែងសណ្តាប់ធ្នាប់នៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត
- បំពេញភារកិច្ចផ្សេងទៀតដែល គឃ.សប និងប្រធាន គ.ក.ប ប្រគល់ឱ្យ។

## III- វិញ្ញាសាដែលត្រូវសម្ភាសន៍

- ចំណេះដឹងទូទៅទាក់ទងនឹងការបោះឆ្នោត
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គ.ជ.ប
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

**IV- រយៈពេលបម្រើការងារចំនួន ៤ថ្ងៃកន្លះ**

- ចូលរួមវគ្គបណ្តុះបណ្តាល ២ថ្ងៃ (ថ្ងៃទី២០ ឬ ថ្ងៃទី២១-៧-២០២៣)
- ទទួល និងត្រួតពិនិត្យសម្ភារ ឯកសារ និងត្រៀមរៀបចំការិយាល័យបោះឆ្នោត ១ថ្ងៃ (ថ្ងៃទី២២-៧-២០២៣)
- ចាត់ចែងការបោះឆ្នោត និងរាប់សន្លឹកឆ្នោត ១ថ្ងៃ (ថ្ងៃទី២៣-៧-២០២៣)
- ប្រគល់សម្ភារ ឯកសារជូន គឃ.សប មួយព្រឹក (ថ្ងៃទី២៤-៧-២០២៣)។

**V- ប្រាក់កម្រៃម៉ៅការសរុប**

| | | |
|---|---|---|
| - ប្រធាន | ប្រាក់កម្រៃទទួលបាន | ៣១៥.០០០ រៀល |
| - អនុប្រធាន | ប្រាក់កម្រៃទទួលបាន | ២៩២.៥០០ រៀល |
| - លេខាធិការ | ប្រាក់កម្រៃទទួលបាន | ២៧០.០០០ រៀល |
| - សមាជិកទី១ | ប្រាក់កម្រៃទទួលបាន | ២៤៧.៥០០ រៀល |
| - សមាជិកទី២ | ប្រាក់កម្រៃទទួលបាន | ២៤៧.៥០០ រៀល |
| - សមាជិកទី៣ | ប្រាក់កម្រៃទទួលបាន | ២៤៧.៥០០ រៀល ។ |

**VI- ទំនាក់ទំនងព័ត៌មាន**

សាធារណជនដែលមានបំណងដាក់ពាក្យជាបេក្ខជនតាមមុខតំណែងខាងលើ សូមអញ្ជើញមកទំនាក់ទំនងព័ត៌មាន ឬមើលសេចក្តីជូនដំណឹងនៅ គឃ.សប ឬតាមទីសាធារណៈដែលបានបិទផ្សាយក្នុងឃុំ សង្កាត់។

ពាក្យសុំចូលបម្រើការងារនឹងមានចែកជូនដោយឥតគិតថ្លៃរៀងរាល់ម៉ោងធ្វើការនៅតាម គឃ.សប ឬតាមទីសាធារណៈក្នុងឃុំ សង្កាត់ដែលកំណត់ដោយ គឃ.សប ពាក់ព័ន្ធ។

**VII- កាលបរិច្ឆេទនៃការទទួលពាក្យ និងធ្វើសម្ភាសន៍**

ការទទួលពាក្យសុំចូលបម្រើការងារនឹងធ្វើនៅ គឃ.សប ឬតាមទីកន្លែងដែលកំណត់ដោយ គឃ.សប ៖

- ការចាប់ផ្តើមចែកពាក្យ និងទទួលពាក្យ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២៣ (វេលាម៉ោង ៧:០០ ព្រឹក)
- ការឈប់ទទួលពាក្យ ថ្ងៃទី៤ ខែកក្កដា ឆ្នាំ២០២៣ (វេលាម៉ោង ១៧:៣០ នាទីល្ងាច)
- ការបិទផ្សាយបញ្ជីឈ្មោះបេក្ខជនដែលត្រូវធ្វើសម្ភាសន៍ចន្លោះពីថ្ងៃទី៥ ដល់ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២៣ នៅតាម គឃ.សប
- ការធ្វើសម្ភាសន៍នៅតាម គឃ.សប ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៣។

**VIII- ការអនុវត្តតាមបទបញ្ជាផ្ទៃក្នុងនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

បន្ទាប់ពីការចែកពាក្យ និងទទួលពាក្យរួច គឃ.សប ត្រូវពិនិត្យសំណុំលិខិតរបស់បេក្ខជន និងត្រូវធ្វើការពិនិត្យ និងជ្រើសរើសយកបេក្ខជនដែលមានលក្ខខណ្ឌល្អជាងគេ ៣រូប សម្រាប់មួយមុខតំណែង ដើម្បីមកសម្ភាសន៍។ សំណុំលិខិតរបស់បេក្ខជនមិនត្រូវប្រគល់ជូនវិញទេ។

## IX- លទ្ធផលនៃការធ្វើសម្ភាសន៍

លទ្ធផលនៃការធ្វើសម្ភាសន៍នឹងបិទផ្សាយនៅតាមគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត។

**បញ្ជាក់បន្ថែម** ÷

- សញ្ញាបត្រ ឬ/និងលិខិតបញ្ជាក់ពីបទពិសោធន៍ការងារត្រូវធ្វើនីត្យានុកូលកម្ម ឬមានការបញ្ជាក់ពីសាមីស្ថាប័ន
- គ្រប់បេក្ខជនត្រូវមានអ្នកធានាដឹងឮ យ៉ាងតិចមួយនាក់
- បេក្ខជនទាំងអស់ត្រូវធានាថា ក្រោយពីពេលដែលត្រូវបានជ្រើសរើសឱ្យចូលបម្រើការងារក្នុងមុខតំណែងណាមួយនោះ ត្រូវសុខចិត្តទទួលយកប្រាក់កម្រៃដូចបានកំណត់ ហើយនឹងត្រូវបើកជូនក្រោយពី គ.ជ.ប បានទទួលប្រាក់ពីរតនាគារជាតិ
- យោងតាមមាត្រា២៦ នៃអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចែងថា «... មន្ត្រីរាជការ ដែលត្រូវបានជ្រើសរើសពីក្រសួង ស្ថាប័ននានា ជាមន្ត្រីជាប់កិច្ចសន្យាបម្រើការងារឱ្យ គ.ជ.ប ត្រូវបានរក្សាបៀវត្ស ប្រាក់បំណាច់ផ្សេងៗ អតីតភាពការងារ សម្រាប់ការឡើងថ្នាក់ និងទទួលសោធននិវត្តន៍នៅអង្គភាពដើមរបស់ខ្លួនដដែល »
- ការសូក និងទទួលសំណូកគឺជាអំពើខុសច្បាប់ ដែលត្រូវផ្ដន្ទាទោសតាមច្បាប់។

ថ្ងៃ ចន្ទ ៣កើត ខែ អាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០២៣

ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

ប្រាជ្ញ ចន្ទ